# រឿង ក្រពើ និងអ្នកបររទេះ



# រឿង ក្រពើ និងអ្នកបររទេះ



នៅរដូវប្រាំងមួយ ទឹកបឹងត្រពាំងរីងស្ងួតអស់ ។ ពេលនោះ មានសត្វក្រពើមួយវារ
ឡើងគោក ដើម្បីស្វែងរកទីណាមួយដែលមានទឹក ។





ជួនជាពេលនោះ វាបានជួបនឹងបុរសម្នាក់កំពុងបររទេះនៅតាមផ្លូវ ។ ក្រពើបាន សុំអង្វរបុរសបររទេះនោះឱ្យជួយ "លោកអើយ! មេត្តាជួយយកខ្ញុំទៅរកកន្លែងណាដែលមានទឹកផង ខ្ញុំនឹងមិនភ្លេចគុណលោកអស់មួយជីវិត!" ។







ស្តាប់ការអង្វរករបស់ក្រពើហើយ អ្នកបររទេះក៏យល់ព្រម ទើបគាត់ដោះគោចេញពីនឹម ហើយលើកក្រពើដាក់សណ្តូកលើទូករទេះ ។ ក្រពើមិនទុកចិត្តក្រែងធ្លាក់ ក៏សុំឱ្យអ្នកបររទេះចងភ្ជាប់ខ្លួនទៅនឹងទូករទេះ ។ អ្នកបររទេះក៏ព្រមធ្វើតាមការបង្គាប់របស់ក្រពើ ។ ពេលចងភ្ជាប់រួច គាត់ក៏បររទេះចេញទៅ ។





លុះបានទៅដល់មាត់បឹងហើយ  អ្នកបររទេះក៏ស្រាយក្រពើចេញ ហើយប្រាប់ថា
“ទីនេះមានទឹកត្រជាក់អាចរស់នៅបានស្រួល ចូរអ្នកវារចុះទៅ!” ។





ឯក្រពើជាសត្វរមិលគុណ វាបានប្រកែកថា "អ្នកឯងចងភ្ជាប់ខ្ញុំនឹងទូករទេះតឹងខ្លាំងណាស់ ខ្ញុំមិនសុខចិត្តទេ ។ ឥឡូវនេះ អ្នកត្រូវឱ្យគោមួយមកខ្ញុំស៊ី បើមិនដូច្នោះទេ ខ្ញុំនឹងស៊ីអ្នក" ។





អ្នកបររទេះឮក្រពើនិយាយដូច្នោះ គាត់ភ័យខ្លាំងណាស់ ខំនិយាយអង្វរក្រពើថា "ខ្ញុំបានធ្វើគុណចំពោះអ្នក ម្ដេចបែរជាមានទោសទៅវិញ ? ។ ដូច្នេះ ខ្ញុំសុំទៅរកចៅក្រមមកជួយកាត់ក្ដីរឿងនេះ" ។ ក្រពើតបថា បើអ្នកមិនសុខចិត្តទេ ទៅរកចៅក្រមចុះ ។





មិនបង្អង់យូរ  អ្នកបររទេះក៏បានដើរទៅរកសុភាទន្សាយ ។

នៅពេលបានជួបហើយ  អ្នកបររទេះក៏
និយាយប្រាប់សុភាទន្សាយឱ្យបានដឹងរឿងសព្វគ្រប់។

ក្រោយពីបានដឹងរឿងហើយ  សុភាទន្សាយក៏ឱ្យ
អ្នកបររទេះជូនទៅជួបនឹងក្រពើដើម្បីជំនុំជម្រះក្តី ។





នៅពេលបានជួបនឹងសុភាទន្សាយភ្លាម  ក្រពើក៏ប្រញាប់ប្រាប់ពីដំណើររឿង ដែលអ្នកបររទេះបានចងភ្ជាប់វាយ៉ាងតឹង ដកដង្ហើមសឹងពុំរួច ។ ដូច្នេះ ត្រូវតែឱ្យគោមកវាមួយស៊ីជាអាហារ ។





ភ្លាមនោះ អ្នកបររទេះបានប្រកែក តែសុភាទន្សាយបង្គាប់ឱ្យអ្នកបររទេះ
និងក្រពើធ្វើសកម្មភាពនោះឡើងវិញ ។





ក្រពើក៏ឱ្យអ្នកបររទេះលើកវាដាក់សណ្ដូកលើទូកររទេះ ដូចលើកពីមុន ។
សុភាទន្សាយសួរថា "មើល៍! ប្អូនក្រពើ! ពីមុន អ្នកបររទេះបានចងប្អូនតឹងយ៉ាងនេះឬ?"
ក្រពើប្រញាប់ឆ្លើយប្រកែកថា "ទេ! ទេ គាត់បានចងខ្ញុំតឹងជាងនេះខ្លាំងណាស់!" ។



សុភាទន្សាយបង្គាប់ឱ្យអ្នកបររទេះកាប់មែកឈើមកធ្វើជាកូនកំព្រា ដើម្បីរឹត
ឱ្យតឹងជាងមុន ។ អ្នកបររទេះរឹតកូនកំព្រាអស់ពេញទំហឹង ។ ក្រពើឈឺ ស្រែកថា
"គាត់ចងតឹងយ៉ាងនេះ សូមមេត្តារកខុសត្រូវឱ្យខ្ញុំផង" ។
ឃើញដូច្នេះ សុភាទន្សាយឃាត់អ្នកបររទេះកុំឱ្យស្រាយចំណងក្រពើរមិលគុណនោះ ។
ក្រពើដកដង្ហើមស្ទើរមិនរួច រកកលនឹងស្លាប់ម្ដងៗ ។ ពេលនោះទើបវានឹកឃើញ
កំហុសរបស់វា ។



ហើយក៏អង្វរអ្នកបរទេះ និងសុភាទន្សាយ សុំលើកលែងទោស ។
ក្រោយមក អ្នកបរទេះ និងសុភាទន្សាយក៏ព្រមដោះលែងក្រពើ ឱ្យវាទៅបឹងដែល
មានទឹកនៅជិតនោះ ៕



# រឿង ក្រពើ និងអ្នកបររទេះ

និពន្ធ និងរៀបរៀងឡើងវិញដោយ អង្គការសន្តិស្ម័គ្រចិត្ត (SVA)
គូររូបដោយ លោក សេង វិសាល
រក្សាសិទ្ធិដោយ អង្គការសន្តិស្ម័គ្រចិត្ត(SVA)
បោះពុម្ពឆ្នាំ ២០១៥

*Move forward, hand in hand.*

Shanti Volunteer Association

*Stand with people in need around the world.*